ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧៥-សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០១១ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤/អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ

និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣១/អនក្រ/បក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១: បង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈមានសមាសភាព ដូចខាងក្រោមៈ

១- ឯកឧត្តម **គាត ឈន់**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
២- ឯកឧត្តម **ជា ចាន់តូ**	ទេសាភិបាលធនាគារជាតិ នៃកម្ពុជា	អនុប្រធាន
៣- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធានប្រចាំការ
៤- លោកជំទាវ **នាវ ច័ន្ទថាណា**	ទេសាភិបាលរង ធនាគារជាតិ នៃកម្ពុជា	សមាជិក
៥- ឯកឧត្តម **វង្សី វិស្សុត**	អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦- ឯកឧត្តម **ចាន់ សុធី**	អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧- លោកស្រី **ខួន សុខា**	អគ្គនាយកបច្ចេកទេស ធនាគារជាតិ នៃកម្ពុជា	សមាជិក

ប្រការ២: គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល មានមុខងារ និងភារកិច្ចដូចតទៅ:

- រៀបចំ និងត្រួតពិនិត្យការអនុវត្តចក្ខុវិស័យ និងគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
- ពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ មុននឹងដាក់សុំការសម្រេចពីនាយករដ្ឋមន្ត្រី
- ធ្វើជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលគោលនយោបាយពាក់ព័ន្ធ ដើម្បីធានាឱ្យមានសង្គតិភាពរវាងកិច្ចដំណើរការគ្រប់គ្រងបំណុលសាធារណៈ ជាមួយនឹងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ ថវិកា និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ។

ប្រការ៣: គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនក្នុងរយៈពេល ៦ ខែ មួយដង តាមការអញ្ជើញរបស់ប្រធាន ឬអាចប្រជុំញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ ។

ប្រការ៤: គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចបង្កើតគណៈកម្មការ ឬក្រុមការងារផ្សេងៗទៅតាមការចាំបាច់ ដើម្បីសម្របសម្រួលការរៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាពកម្មវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ។

ប្រការ៥: ប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមិនមែនជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យចូលរួមប្រជុំតាមតម្រូវការចាំបាច់នៃការងារ ។

ប្រការ៦: ក្នុងករណីអវត្តមាន សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈអាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីចាត់តាំងមន្ត្រីពាក់ព័ន្ធឱ្យចូលរួមប្រជុំជំនួស ។ សមាជិកគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារគ្រប់គ្រងបំណុលសាធារណៈចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ ។

ប្រការ៧: គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការបច្ចេកទេសរបស់ខ្លួនក្នុងការបំពេញការងារ ។

ប្រការ៨: គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន ។

ប្រការ៩: រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ១០: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ